# សុន្ទរកថារបស់ លោក ឈិត សំអាត
## នាយកប្រតិបត្តិ វេទិកា អង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum on Cambodia)
## ក្នុងឱកាសប្រារព្ធទិវាអន្តរជាតិស្តីពីជនជាតិដើមភាគតិចពិភពលោកលើកទី ១២
## ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០៦

សូមគោរពឯកឧត្តម **លី ឡាយស្រេង** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ
ឯកឧត្តម លោកជំទាវ លោក-លោកស្រី តំណាងក្រសួងនិងស្ថាប័នពាក់ពន្ធ័ជាទីគោរព
ភ្ញៀវកិត្តិយសទាំងអស់ តំណាងឱ្យអង្គការជាតិ និងអន្តរជាតិ បងប្អូនតំណាងឱ្យជនជាតិដើមភាគតិចមកពី ១៩ ខេត្តនានា ក្នុងព្រះរាជាណាចក្រកម្ពុជា ជាទីរាប់អាន

តាងនាមឱ្យ វេទិកា អង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum) ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ដែលបានចូលរួមចែករំលែក ការយល់ដឹងមួយចំនួនទាក់ទងនឹងការរៀបចំទិវាអន្តរជាតិស្តីពីជនជាតិដើមភាគតិចពិភពលោកលើកទី ១២ ហើយនេះជាលើកទី ២ ដែលទិវានេះបានប្រារព្ធនៅប្រទេសកម្ពុជា។ នេះជាព្រឹត្តិការណ៍មួយដ៏សំខាន់សំរាប់ជនជាតិដើមភាគតិចទាំងអស់នៅកម្ពុជា និងក្នុងប្រទេសជាង ៧0 ទូទាំងពិភពលោក។ ទន្ទឹមគ្នានេះដែរ នេះជាឱកាស ដែលផ្តល់ ឱ្យយើងពិនិត្យលើការអភិវឌ្ឍន៍សំខាន់ៗដើម្បី ជួយដល់ជនជាតិដើម ភាគតិច។

ក្នុងឆ្នាំ ២០០៤ មហាសន្និបាតអង្គការសហប្រជាជាតិបានប្រកាសពីទសវត្សរ៍អន្តរជាតិលើកទី ២ សំរាប់ជនជាតិដើមពិភពលោក។ ទសវត្សរ៍លើកទី២នេះ ចាប់ផ្តើមនៅខែមករា ឆ្នាំ ២០០៥ ដោយមានគោលបំណងក្នុងការបន្តពង្រឹងសហប្រតិបត្តិការអន្តរជាតិ ដើម្បីដោះស្រាយបញ្ហា ដែលបងប្អូនជនជាតិដើមជួបប្រទះ។ ការប្រារព្ធទិវាថ្ងៃនេះជាឱកាសសំរាប់យើងធ្វើការឆ្លុះបញ្ចាំង នូវការផ្លាស់ប្តូរជាវិជ្ជមាន និង ឧបសគ្គ ដើម្បីយើងប្រឈមទាក់ទងនិង ស្ថានភាពដែលជនជាតិដើមភាគតិចជួបប្រទះ ។ មានការទទួលស្គាល់ ជាទូលំទូលាយ ថាការកំណត់ស្វ័យភាពនៃការអភិវឌ្ឍន៍សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា បានបង្ហាញពីការចូលរួមវិភាគ ទានដ៏មានសារៈសំខាន់ ដើម្បីសំរេចបាននូវគោលដៅនៃការអភិវឌ្ឍន៍សហសវត្សរ៍ នៅឆ្នាំ ២០១៥។

ទាក់ទងនឹងការជំរុញឱ្យមានការគោរពសិទ្ធិរបស់ប្រជាជនជាជាតិដើមភាគតិចលើឆាកអន្តរជាតិ ការអនុម័តនៃសេចក្តីប្រកាសស្តីពីសិទ្ធិជនជាតិដើមភាគតិចក្នុងកិច្ចប្រជុំលើកទី១នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស ក្នុងខែមិថុនា គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំរាប់ជនជាតិដើមភាគតិចទាំងអស់ក្នុងពិភពលោក។ នៅពេលដែលសេចក្តីប្រកាសនេះត្រូវបានផ្តល់សច្ចាប័នដោយមហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីប្រកាសនេះ និងអនុសញ្ញា ១៦៩ របស់អង្គការពលកម្មអន្តរជាតិស្តីពីជនជាតិដើមភាគតិចនិងកុលសម្ពន្ធ័ និងក្លាយជាវិធានច្បាប់អន្តរជាតិដ៏មានសារៈសំខាន់សំរាប់ការពារ និង លើកស្ទួយសិទ្ធិរបស់ជនជាតិដើមភាគតិច។

សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិបានទទួលស្គាល់សិទ្ធិជនជាតិដើមភាគតិច ជាម្ចាស់កាន់កាប់ និងប្រើប្រាស់លើដីធ្លីនិងធនធានធម្មជាតិតាមបែបប្រពៃណី។ សេចក្តីប្រកាសតំរូវឱ្យ ប្រទេសនានាការពារនិងផ្តល់ការ

ទទួលស្គាល់ស្របច្បាប់ដល់ដីធ្លី និងធនធានធម្មជាតិទាំងនោះ។ ជាមួយគ្នានេះដែរ អនុសញ្ញា ១៦៩ របស់អង្គការពលកម្មអន្តរជាតិ បានអំពាវនាវឱ្យរដ្ឋាភិបាលកំណត់នូវដីធ្លី ដែលកាន់កាប់ដោយជនជាតិដើមភាគតិចតាមបែបប្រពៃណី និងធានានូវការការពារសិទ្ធិជនជាតិដើមភាគតិចប្រកបដោយប្រសិទ្ធភាព។

ប្រទេសកម្ពុជាបានចាប់ផ្ដើមរៀបចំច្បាប់ និងគោលនយោបាយដែលទាក់ទងនឹងជនជាតិដើមភាគតិច។ ក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១ បានទទួលស្គាល់សិទ្ធិសហគមន៍ជនជាតិដើមភាគតិចដែលជាម្ចាស់កម្មសិទ្ធិ សមូហភាពលើដីធ្លី ដែលពួកគេកាន់កាប់។ សេចក្ដីព្រាងគោលនយោបាយសំរាប់អភិវឌ្ឍន៍ជនជាតិដើមភាគតិច ត្រូវបានរៀបចំរួចរាល់។ នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិដើមភាគតិចកំពុងធ្វើការជាមួយទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីជំរុញឱ្យមានការអនុម័ត។ លក្ខន្តិកស្ដីពីសហគមន៍ជនជាតិដើមភាគតិច កំពុងត្រូវបានរៀបរៀងដោយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ ដោយមានការសហការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ។ ទោះជាយ៉ាងណាក្ដី អនុក្រិត្យដែលតំរូវឱ្យមានការចុះបញ្ជីដីសមូហភាពពុំទាន់ត្រូវបានអនុមត័នៅឡើយ ។ ជនជាតិដើមភាគតិច នៅកម្ពុជានៅតែបន្តការបាត់បង់ដីប្រពៃណីរបស់ពួកគេ ដែលដីធ្លីជាមូលដ្ឋានសំរាប់ការរស់រានមានជីវិត និងជាប្រភពចំណូលដ៏ចំបងរបស់ពួកគេ។

NGO Forum ជាថ្មីម្ដងទៀត សូមថ្លែងនូវការកោតសរសើរដល់ការយកចិត្តទុកដាក់និងការគាំទ្រ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំទិវាអន្តរជាតិស្ដីពីជនជាតិដើមភាគតិចពិភពលោកនេះឡើងក្នុងប្រទេសកម្ពុជា។ យើងសូមអបអរសាទរដល់រាជរដ្ឋាភិបាលដែលបានប្ដេជ្ញាជំរុញឱ្យមានការអនុមត័ និងអនុវត្តច្បាប់និងគោលនយោបាយជាតិផ្សេងៗ ដើម្បីទទួលស្គាល់និងរក្សាវប្បធម៌ អត្តសញ្ញាណ និងបែបបទនៃការរស់នៅរបស់ជនជាតិដើមភាគតិច នៅកម្ពុជា ។ យើងខ្ញុំសូមសំនូមពរឱ្យរាជរដ្ឋាភិបាល និង ស្ថាប័នពាក់ព័ន្ធទាំងអស់មេត្តាបន្តការយកចិត្តទុកដាក់ពិសេស ដើម្បីធានាសិទ្ធិជនជាតិដើមភាគតិចជាម្ចាស់លើធនធានធម្មជាតិ រួមមាន ដី និងព្រៃឈើ។ សហគមន៍ NGO សូមប្ដេជ្ញា ក្នុងការធ្វើការសហការណ៍ជាមួយរដ្ឋាភិបាល និងគ្រប់ភាគីពាក់ពន្ធ័ទាំងអស់ ដើម្បីសំរេចនូវគោលបំណងនេះ ។

ជាទីបញ្ចប់ ខ្ញុំសូមយកឱកាសនេះថ្លែងនូវអំណរគុណដ៏ជ្រាលជ្រៅដល់រាជរដ្ឋាភិបាល ជាពិសេស ក្រសួងអភិវឌ្ឍន៍ជនបទ ស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលធ្វើការរួមគ្នាក្នុងការរៀបចំ ទិវាអន្តរជាតិស្ដីពីជនជាតិដើមភាគតិច ពិភពលោកនេះប្រកបដោយជោគជ័យ។

សូមជូនពរដល់គណអធិបតី ឯកឧត្តម លោកជំទាវ លោក-លោកស្រី ឱ្យជួបប្រទះតែពុទ្ធពរទាំងប្រាំប្រការ កុំបីឃ្លៀង ឃ្លាតឡើយ។

អបអរសាទរ **ទិវាអន្តរជាតិស្ដីពីជនជាតិដើមភាគតិចពិភពលោកលើកទី ១២!**

***សូមអរគុណ!***